**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សារលិខិតថ្វាយព្រះពរ

## សូមក្រាបថ្វាយបង្គំទូលថ្វាយ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

***ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !***

ក្នុងទិវាដ៏សោមនស្សរីករាយ នាឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ៦២ យាងចូល ៦៣ ព្រះវស្សារបស់ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងនាមទូលព្រះបង្គំជាខ្ញុំ និងក្រុមគ្រួសារ សូមព្រះបរមរាជានុញ្ញាតសំដែងថ្វាយនូវព្រះសព្ទសាធុការពរបវរសួស្តី សិរីមង្គលមហាប្រសើរថ្វាយ **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** សូមព្រះអង្គមានព្រះបញ្ញាញាណឈ្លាសវៃ ភ្លឺថ្លា ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់នៅក្នុងព្រះបរមរាជសម្បត្តិ ជាម្លប់ត្រជាក់ត្រជុំដល់ប្រជារាស្ត្រខ្មែរគ្រប់រូបយូរអង្វែងតរៀងទៅ។

ទូលព្រះបង្គំជាខ្ញុំ សូមសំដែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះរាជបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ដើម្បីជាតិ និងប្រជារាស្ត្រលើគ្រប់វិស័យ ជាពិសេសវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំ សូមធ្វើអភិវន្ទនកិច្ចថ្វាយព្រះពរបវរមហាប្រសើរ និងសូមលើកហត្ថទាំងទ្វេប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី មហិទ្ធិឫទ្ធិទេវតារក្សាព្រះមហាស្វេតច័ត្រ ទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ព្រមទាំងព្រះវិញ្ញាណក្ខ័ន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ និងដួងព្រះវិញ្ញាណក្ខ័ន្ធព្រះបរមរតនៈកោដ្ឋ សូមតាមប្រោះព្រំ ទ្រទ្រង់គាំពារ ថ្វាយព្រះពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** សូមទ្រង់សមប្រកបដោយពុទ្ធពរទាំង៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ទ្រង់ព្រះមេត្តាប្រោសទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ អំពីទូលព្រះបង្គំជាខ្ញុំ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ខែឧសភា ឆ្នាំ២០១៥*

**តំណាងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**